ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

*ថ្ងៃ អង្គារ ១៣ រោច ខែ ពិសាខ ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០២០*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលនៃកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នាព្រឹកថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០២០ វេលាម៉ោង ០៩:០០នាទីព្រឹក, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានរៀបចំកិច្ចប្រជុំកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយមានការចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ និងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ កិច្ចប្រជុំនេះបានរៀបចំតាមរយៈប្រព័ន្ធវីឌីអូ ដោយប្រើប្រាស់ប្រព័ន្ធ Intranet របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរបៀបវារៈដូចតទៅ÷

១. ពិនិត្យវឌ្ឍនភាពប្រចាំឆ្នាំ ២០១៩ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ និង

២. ពិនិត្យវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី ៣ ឆ្នាំ ២០១៦-២០១៩ និងការត្រៀមរៀបចំក្របខណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី ៤ ។

ខ្លឹមសារសំខាន់ៗ តាមរបៀបវារៈនីមួយៗ មានដូចតទៅ÷

***១. វឌ្ឍនភាពប្រចាំឆ្នាំ ២០១៩ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣***

ការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំ ២០១៩ សម្រេចបានវឌ្ឍនភាពល្អប្រសើរលើគ្រប់ផ្នែកនៃផែនការសកម្មភាពរួម ដំណាក់កាលទី ៣ ក្នុងនោះរួមមានដូចតទៅ÷

- ***ភាពជឿទុកចិត្តនៃថវិកា*** នៅតែអាចរក្សាបានជាសារវន្ត ដោយសារប្រសិទ្ធភាពនៃការអនុវត្តផែនការប្រមូលចំណូលសម្រេចបាន ១២៨,២% នៃច្បាប់ថវិកាឆ្នាំ២០១៩ ឬស្មើ ២៧ ១៥៩ ប៊ីលានរៀល និងចំណាយថវិកាជាតិសម្រេចបាន ៩៥,៤% ឬស្មើ ១៩ ៧៥១ ប៊ីលានរៀល (ទិន្នន័យបណ្តោះអាសន្ន) ។
- ***ប្រព័ន្ធគណនេយ្យភាពហិរញ្ញវត្ថុ*** ត្រូវបាន និងកំពុងកសាងតាមរយៈការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជំហានទី ១ និងទី ២ ។ មកពេលនេះ, ប្រព័ន្ធ FMIS

ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្នាក់កណ្តាលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, រតនាគាររាជធានី-ខេត្ត, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី-ខេត្ត និងក្រសួង-ស្ថាប័នចំនួន ៣៧ ។

- ***ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី*** ជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំ និងកំណត់ការផ្លាស់ប្តូរប្រព័ន្ធថវិកាកម្ពុជា ដើម្បីឱ្យក្លាយជាឧបករណ៍សម្រាប់ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ។ គិតត្រឹមឆ្នាំ ២០១៩ ថវិកាកម្មវិធីត្រូវបានដាក់ឱ្យអនុវត្តគ្រប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលខេត្តចំនួន ១៨ ហើយរដ្ឋបាលរាជធានី-ខេត្តផ្សេងទៀតនឹងត្រូវដាក់ឱ្យអនុវត្តជាបន្តបន្ទាប់រហូតដល់ឆ្នាំ ២០២១ ។
- ***សម្រាប់ការត្រៀមខ្លួនជំហានបន្ទាប់ ឬ គណនេយ្យភាពសមិទ្ធកម្ម*** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបាននិងកំពុងរៀបចំច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុថ្មី, កែសម្រួលអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈ និងអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលកម្ពុជា បានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥, យុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ ២០១៩-២០២៣, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ ២០១៩-២០២៥, យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈឆ្នាំ ២០១៩-២០២៥ និងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ ២០១៩-២០២៣ ហើយយុទ្ធសាស្ត្រនីមួយៗ មានផែនការ សកម្មភាពលម្អិត ដើម្បីឱ្យការអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ, ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ។
- ជាយន្តការសម្រាប់ការគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយជោគជ័យ និងចីរភាព, ក.ស.ហ.វ. បានបណ្តុះបណ្តាលមន្ត្រីរាជការនៃ ក.ស.ហ.វ. និងក្រសួង-ស្ថាប័នចំនួន ១០៥៩ លើជំនាញសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយកំពុងរៀបចំការបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ និងរៀបចំផែនការយុទ្ធសាស្ត្រស្តីពីការកសាងនិងអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤ ។

## ***២- ពិនិត្យវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី ៣ ឆ្នាំ២០១៦-២០១៩ និងការត្រៀមរៀបចំក្របខណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី ៤***

ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ ឆ្នាំ២០១៦-២០១៩ សម្រេចបានវឌ្ឍនភាពតាមការគ្រោងទុក ជាពិសេសលើការរៀបចំយុទ្ធសាស្ត្រ, ផែនការ និងគោលការណ៍ណែនាំ ដែលបានបង្កើតជាមូលដ្ឋានគ្រឹះ ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ។

ជាមួយគ្នានេះ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បាននិងកំពុងរៀបចំរបាយការណ៍វាយតម្លៃចំណាយសារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឆ្នាំ ២០២០ ដែលមានការគាំទ្រជាជំនួយបច្ចេកទេសពីសហភាពអឺរ៉ុប និងមូលនិធិរូបិយវត្ថុអន្តរជាតិ ដែលគ្រោងបញ្ចប់ក្នុងឆ្នាំ ២០២០ នេះ ។ លទ្ធផលនៃការវាយតម្លៃការអនុវត្តផែនការសកម្មភាព រួម ដំណាក់កាលទី ៣ និង PEFA នឹងក្លាយជាធាតុចូលដ៏សំខាន់សម្រាប់រៀបចំក្របខណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី ៤ ។

ជាទីបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍ណែនាំគ្រប់អង្គភាពក្រោមឱវាទ ក.ស.ហ.វ. បន្តជំរុញការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី ៣ និងការងារប្រទាក់ក្រឡាគ្នារវាងការដ្ឋានកែទម្រង់បី បូកមួយ (ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, វិមជ្ឈការ និងវិសហមជ្ឈការ, រដ្ឋបាលសាធារណៈ និង ច្បាប់និងប្រព័ន្ធយុត្តិធម៌) ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ជូនពរគ្រប់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជួបប្រទះតែពុទ្ធពរទាំង ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។